**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើត គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

** * **

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០២

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

ត្រូវបានបង្កើតគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ សរសេរកាត់ គ.ប.ច ជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងអប់រំ យុវជន និងកីឡា និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

. គ.ប.ច. មានទីស្នាក់ការអគារលេខ ១៤៨ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

. គ.ប.ច. គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២ .–**

គ.ប.ច. មានទិសដៅធ្វើអាជីវកម្មបោះពុម្ពផ្សាយ និងចែកផ្សាយ :

- បោះពុម្ពផ្សាយសៀវភៅសិស្ស និងសៀវភៅគ្រូ ដែលមានគុណភាពក្នុងការរៀន និងការបង្រៀនគ្រប់មុខវិជ្ជានៅបឋមសិក្សា និងមធ្យមសិក្សា
- បោះពុម្ពផ្សាយសៀវភៅអានបន្ថែម សៀវភៅលំហាត់សម្រាប់សិស្ស ព្រមទាំងសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូ ទស្សនាវដ្តីផ្សេងៗ ដែលទាក់ទងនឹងវិស័យអប់រំ សុខាភិបាល ។ល។ និង ។ល។
- អភិវឌ្ឍ និងផលិតសម្ភារៈឧបទេសងាយៗ សម្រាប់ជំនួយដល់គ្រូ ក្នុងការបង្រៀន
- ទទួលសេវាបោះពុម្ពឯកសារផ្សេងៗ ដែលបម្រើផលប្រយោជន៍សាធារណៈ
- ទទួលសេវាដឹកជញ្ជូនសៀវភៅដល់សាលារៀន
- រៀបចំបណ្តាញលក់សៀវភៅសិក្សាគ្រប់ប្រភេទ ដល់គ្រប់ខេត្ត-ក្រុង និងដល់សាលារៀន ។

មាត្រា ៣ .–

ក្នុងការប្រកបអាជីវកម្ម គ.ប.ច. ត្រូវទទួលស្វ័យភាពធំទូលាយ ដើម្បីដឹកនាំគ្រប់គ្រងសកម្មភាព ក្នុងគោលដៅបំពេញបេសកកម្មឱ្យមានប្រសិទ្ធភាព ស្របតាមច្បាប់ជាធរមាន ។

មាត្រា ៤ .–

ដើមទុនដំបូងនៃ គ.ប.ច. ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ពេលដែលអនុក្រឹត្យនេះចូលជាធរមាន គ.ប.ច. ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៥ .–

បុគ្គលិក គ.ប.ច. ត្រូវជ្រើសរើសពីចំណោមមន្ត្រី នៃមុខងារសាធារណៈ របស់ក្រសួងអប់រំ យុវជន និងកីឡា និងអាចជ្រើសរើសតាមកិច្ចសន្យាក្នុងករណីចាំបាច់ ។ បុគ្គលិករបស់ គ.ប.ច. ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ២
## ការដឹកនាំ និង គ្រប់គ្រង

មាត្រា ៦ .–

គ.ប.ច. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទប្បញ្ញត្តិនៃ អនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| - អគ្គនាយក គ.ប.ច | ១ រូប | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| - តំណាងនិយោជិតរបស់ គ.ប.ច. | ១ រូប | សមាជិកស្វ័យប្រវត្តិ |

មាត្រា ៧ .–

សមាជិកក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជំនាញ ដែលបានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជន ដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវបានផ្ដន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ឆ្នាំ។ អាណត្តិនេះអាចបញ្ចប់ និងអាចបន្តទៀតបានតែម្ដងគត់ តាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត គ.ប.ច. ។

មាត្រា ៨ .–

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសម្រេចក្នុងនាមនៃ គ.ប.ច. ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :

- ផ្ដល់ការយល់ព្រមលើគំរោងផែនការរបស់សហគ្រាស ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ
- វាយតម្លៃទៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការ ដើម្បីកែសម្រួលឱ្យបានសមស្របតាមសភាពការណ៍
- ផ្ដល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ គ.ប.ច.
- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈរបស់ គ.ប.ច. ព្រមទាំងលក្ខន្តិកបុគ្គលិក និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សម្រាប់បុគ្គលិកដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន
- ផ្ដល់ការយល់ព្រមលើកិច្ចសន្យា និងកិច្ចព្រមព្រៀងដែល គ.ប.ច. ជាភាគីហត្ថលេខី ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន
- សម្រេចបង្កើត បើក ឬ បិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ គ.ប.ច. តាមការវិនិច្ឆ័យរបស់ខ្លួន
- សម្រេចលើកិច្ចសន្យា តាមប្រកាសលេខ ៩៩៧ សហវ.ទរ. ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលទ្ធកម្មសហគ្រាសសាធារណៈ ។



ឃ

មាត្រា ៩ .—

ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាសតាមការអញ្ជើញរបស់ប្រធាន រឺ តាមសំណើនៃសមាជិកដែលមានចំនួន៣ នាក់យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ដង ក្នុងរយៈពេល ៣ ខែ ។ ករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ ដែលមានអាយុច្រើនជាងគេក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឱ្យបានយ៉ាងតិច១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិច ៣ នាក់ ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំបាច់ទាមទារកូរ៉ុមទេ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល រឺប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១០ .—

សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចម្លងចូលបញ្ជីដែលមានលេខរៀង ទំព័រ ជាហូរហែ និងមានអត្តលេខចំណាំត្រឹមត្រូវ ។

កំណត់ហេតុដើមត្រូវមានចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលវត្តមាន និងលេខាធិការជ្រើសរើសដោយប្រធានអគ្គនាយក គ.ប.ច. ។

មាត្រា ១១ .—

អគ្គនាយកមានភារកិច្ច ជាអ្នកគ្រប់គ្រងការងារ ជាប្រក្រតីនៃ គ.ប.ច. និងត្រូវបានតែងតាំងសម្រាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា ។



ႃ

មាត្រា ១២ .–

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្រួបតាមច្បាប់ ។

ក្នុងក្របខ័ណ្ឌនេះអគ្គនាយកត្រូវ :

- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេច និងចាត់ចែងអនុវត្ត រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនីមួយៗ និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ គ.ប.ច.
- ទទួលដឹកនាំ គ.ប.ច. លើផ្នែករដ្ឋបាល បច្ចេកទេសអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ
- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង រឺបញ្ឈប់ការងារ និងគ្រប់គ្រងបណ្តាភ្នាក់ងារ រឺមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ គ.ប.ច. ដោយគោរពតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងលក្ខន្តិកបុគ្គលិក រឺច្បាប់ជាធរមាន ។
- មានសិទ្ធិផ្ទេរអំណាចមួយភាគ រឺទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខា ទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- តំណាងឱ្យ គ.ប.ច. និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់ តវ៉ាការពារក្តីឱ្យ គ.ប.ច. និងប្តឹងជំទាស់ផ្សេងៗ ។

មាត្រា ១៣ .–

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៤ .–

ការចុះ និងការអនុវត្តកិច្ចសន្យាដោយ គ.ប.ច. ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយលក្ខន្តិកៈរបស់គ្រឹះស្ថានសាធារណៈ និងច្បាប់ជាធរមាន ។

## ជំពូកទី ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៥ .–

គ.ប.ច. កាន់កាប់គណនេយ្យរបស់ខ្លួនឱ្យបានសមស្រប តាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។



ych

ការិយបរិច្ឆេទគណនេយ្យ ចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី ៣១ ខែ មីនា នៃឆ្នាំបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាល បានពិនិត្យឯកសារទាំងឡាយ ។

ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ១៦ នៃព្រះរាជក្រមលេខ ជស/ រកម/ ០៦៩៦ /០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៦ .–**

រៀងរាល់ឆ្នាំ មុនថ្ងៃទី ០១ ខែ តុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគំរោង ផែនការប្រចាំឆ្នាំតាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧ .–**

ធនធាននៃ គ.ប.ច. ជាអាទិ៍មាន :

- ដើមទុនដែលរដ្ឋផ្តល់ឱ្យ (តុល្យការដំបូង នៅពេលបង្កើត)
- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យបន្ថែម
- ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីអាជីវកម្មរបស់គ.ប.ច.
- ប្រាក់បានមកពីការលក់ រឺការជួលចលនវត្ថុ និងអចលនវត្ថុរបស់ គ.ប.ច
- ប្រាក់ដែលរដ្ឋឧបត្ថម្ភ និងប្រាក់ជាអំណោយផ្សេងៗ ។

**មាត្រា ១៨ .–**

ចំណាយនៃ គ.ប.ច. រួមមាន :

- ចំណាយប្រក្រតីសម្រាប់ដំណើរការ
- ចំណាយវិនិយោគ
- សងបំណុល
- ចំណាយផ្សេងៗ ។

**មាត្រា១៩ .-**

គ.ប.ច. អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសម្រាប់តម្រូវការរបស់ខ្លួន ។

**មាត្រា២០ .-**

គ.ប.ច. ត្រូវបង់ប្រាក់ចំណេញពិតប្រចាំឆ្នាំ ចូលថវិការដ្ឋចំនួន ៥០% ហើយរដ្ឋក៏អាចទុកប្រាក់ចំណេញនេះ ឱ្យសហគ្រាសផងដែរ ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា សហគ្រាសត្រូវធ្វើការអភិវឌ្ឍចាំបាច់ ។ ប្រាក់ចំណេញដែលនៅសល់ ក្រោយពីការបង់ចូលថវិការដ្ឋខាងលើ គ.ប.ច. មានសិទ្ធិប្រើប្រាស់ឱ្យស្របតាមលក្ខន្តិកៈរបស់សហគ្រាស ។

**មាត្រា២១ .-**

រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២២ .-**

រយៈពេល ១៥ថ្ងៃយ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល គ.ប.ច. ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ :

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស
- របាយការណ៍ស្តីពីសកម្មភាព - របាយការណ៍ហិរញ្ញវត្ថុទាំងឡាយរបស់ គ.ប.ច. ។

**មាត្រា២៣ .-**

ត្រូវបានដាក់ឱ្យនៅអម គ.ប.ច. នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់ លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រាទី ២០ ដល់មាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

**មាត្រា២៤ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកនិរាករណ៍ ។

**មាត្រា២៥ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- ឯកសារ - កាលប្បវត្តិ